# សវនាការករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និង សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ស្ត្រីក្នុងតុលាការកម្ពុជា

## អ្វីជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌?

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ផ្តល់ឱ្យបុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌអ្វីមួយ ទទួលបាននូវការអនុវត្តដោយយុត្តិធម៌ និងស្មើភាពគ្នា ថ្វីបើរដ្ឋជាអ្នកកំណត់ពីពិរុទ្ធភាព ឬគ្មានទោសរបស់ពួកគេក៏ដោយ។ សិទ្ធិនេះជាធាតុផ្សំដ៏សំខាន់ក្នុងការគោរពនីតិរដ្ឋ និងធានាការគ្រប់គ្រងយុត្តិធម៌មួយដ៏ត្រឹមត្រូវ។




## ក្របខ័ណ្ឌច្បាប់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

មាត្រា១០នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស «មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញសុំឱ្យតុលាការឯករាជ្យ និងមិនលំអៀងពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ដើម្បីសម្រេចលើសិទ្ធិនិងកាតព្វកិច្ច និងលើភាពសមហេតុផលនៃការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌមកលើខ្លួន»។

មាត្រា១៤នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លម្អិតពីធាតុផ្សំផ្សេងៗនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលរួមបញ្ចូលគ្នា ប៉ុន្តែមិនត្រូវបានកម្រិតតែក្នុងបញ្ជីខាងក្រោមនេះទេ៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- ការសន្មតជាមុនថាគ្មានទោស
- សិទ្ធិមានមេធាវី
- ការការពារប្រឆាំងនឹងការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង
- សិទ្ធិប្តឹងទាស់ទៅតុលាការជាន់ខ្ពស់លើអង្គហេតុនិងអង្គច្បាប់

នៅក្នុងច្បាប់ជាតិ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

## ជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងប្រព័ន្ធយុត្តិធម៌

### តើអំពើហិង្សាទាក់ទងនឹងយេនឌ័រជាអ្វី?

អំពើហិង្សាទាក់ទងនឹងយេនឌ័រសំដៅដល់សកម្មភាពដែលប៉ះពាល់ផ្ទាល់ទៅលើបុគ្គល ដោយផ្អែកលើយេនឌ័ររបស់ពួកគេ ជាពិសេសប្រឆាំងស្ត្រីភេទ។ អំពើហិង្សាទាក់ទងនឹងយេនឌ័រនេះរួមមាន តែមិនកម្រិតត្រឹមសកម្មភាពទាំងនេះទេ ដូចជាអំពើហិង្សាលើស្ត្រី អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាផ្លូវភេទ ដូចជាការរំលោភសេពសន្ថវៈ ការបៀតបៀនផ្លូវភេទ និងការរំលោភសេពសន្ថវៈជាក្រុម(រំលោភបូក) និងការជួញដូរមនុស្ស។



### សិទ្ធិនិងតម្រូវការនៃជនរងគ្រោះនៅក្នុងសវនាការអំពើហិង្សាទាក់ទងនឹងភេទ

ជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវតែទទួលបាននូវយុត្តិធម៌ និងអាចទទួលបាននូវសិទ្ធិដឹងពីការចោទប្រកាន់ទទួលបានដំណោះស្រាយមួយប្រកបដោយប្រសិទ្ធភាព និងអាចទទួលយកបាន តាមរយៈការស៊ើបអង្កេត និងការផ្តន្ទាទោសជនល្មើស។ វាមានសារសំខាន់ដែលប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រដោយគិតគូដល់តម្រូវការជាក់លាក់របស់ជនរងគ្រោះរួមមាន៖

- សុវត្ថិភាពផ្នែករាងកាយ និងផ្លូវចិត្ត
- ការព្យាបាល និងការបាក់ស្បាត
- ការផ្តល់អំណាច និងស្វ័យភាព
- ភាពថ្លៃថ្នូរ និងសិទ្ធិមនុស្ស

# ការពិចារណាចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ និងផលប្រយោជន៍នៃជនរងគ្រោះនៅក្នុងសវនាការករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ

ក្នុងបរិបទនៃសវនាការករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ទោះបីជាសិទ្ធិទទួលបានការជំនុំជម្រះអនុវត្តចំពោះជនជាប់ចោទគ្រប់រូបក្តី ធាតុផ្សំដែលជាទម្រង់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជួនកាលបង្កើតទំនាស់ផលប្រយោជន៍ជាមួយជនរងគ្រោះ។ បទដ្ឋានអន្តរជាតិលើកឡើងថាជញ្ជីងយុត្តិធម៌ត្រូវស្មើគ្នារវាងផលប្រយោជន៍នៃជនជាប់ចោទនិងសុចរិភាពនៃជនរងគ្រោះ។ ជារឿងសំខាន់ដែលថាវិធានសម្រាប់ការពារសិទ្ធិរបស់ជនជាប់ចោទមិនមែនជារនាំងដែលមានភាពលំបាកដល់ការស្វែងរកយុត្តិធម៌។ ឧទាហរណ៍៖

- <u>**ការសន្មតជាមុនថាគ្មានទោស**</u>

  ជាមូលដ្ឋានគ្រឹះនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ ជនជាប់ចោទមានសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសរហូតពិរុទ្ធត្រូវបានកំណត់។ ការសន្មតទុកជាមុននេះជាការដាក់បន្ទុកភស្តុតាងទៅឱ្យព្រះរាជអាជ្ញាត្រូវបង្ហាញពីពិរុទ្ធរបស់ជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យ។

  - ហេតុអ្វីសិទ្ធិនេះមានទំនាស់ផលប្រយោជន៍ជាមួយជនរងគ្រោះ? នៅពេលការជំនុំជម្រះករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ធាតុផ្សំចាំបាច់ធានានូវការចោទប្រកាន់ហួសពីវិមតិសង្ស័យអាចជាបន្ទុកធ្ងន់សម្រាប់ការកាត់ក្តី។ ការបាក់ស្បាតនៃជនរងគ្រោះពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងពេលវេលាដែលបានកន្លងទៅនៅចន្លោះពេលនៃការរំលោភបំពាន និងសវនាការមានផលប៉ះពាល់ដល់សមត្ថភាពនៃការផ្តល់ភស្តុតាងរបស់ជនរងគ្រោះ។ លើសពីនេះការបង្ហាញបញ្ជាក់ពីបទល្មើសដែលជាទូទៅកើតឡើងជាលក្ខណៈឯកជន អាចត្រូវពិបាកបន្ថែមទៀតតាមរយៈការប្រើវិធានប្រុងប្រយ័ត្ន យោងតាមហេតុផលនេះចៅក្រមត្រូវប្រុងប្រយ័ត្ននៅពេលពិចារណាលើភស្តុតាងដែលបង្ហាញដោយសាក្សីមួយចំនួនដូចជាជនរងគ្រោះជាដើម។ ធាតុផ្សំទាំងនេះមានការលំបាកសម្រាប់ការជំនុំជម្រះពីពិរុទ្ធភាព ហេតុនេះហើយទើបអត្រានៃការផ្តន្ទាទោសករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានតិចជាងប្រភេទនៃបទល្មើសផ្សេងទៀតដែលជាការរំលោភបំពានលើសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពរបស់ជនរងគ្រោះ ។

- <u>**គោលការណ៍នៃភាពស្មើគ្នារវាងភាគី**</u>

  គោលការណ៍នេះទាមទារថាភាគីនីមួយៗក្នុងចំណោមភាគីផ្សេងៗទៀត ត្រូវបានផ្តល់ឱកាសដើម្បីតតាំងរាល់អំណះអំណាងភស្តុតាងដែលផ្តល់ដោយភាគីដទៃទៀត។

  - ហេតុអ្វីសិទ្ធិនេះមានទំនាស់ផលប្រយោជន៍ជាមួយជនរងគ្រោះ? ដំណើរការនីតិវិធីនៅតុលាការកម្ពុជាតម្រូវឱ្យជនរងគ្រោះផ្តល់ភស្តុតាងឬត្រូវបានសាកសួរ។ កង្វះខាតនៃការយល់ដឹងផ្នែកយុត្តិធម៌អំពីយេនឌ័រមានន័យថា សំណួរដែលមិនសមរម្យឬការស្តីបន្ទោសឱ្យជនរងគ្រោះកម្រត្រូវបានជំទាស់។ ទង្វើនេះអាចធ្វើឱ្យជនរងគ្រោះមានការបាក់ស្បាតម្តងទៀតឬបំបាក់ទឹកចិត្តរបស់ពួកគេក្នុងការចូលរួមសវនាការ។

## ឧបសគ្គដែលជាបទដ្ឋានសង្គមសម្រាប់យុត្តធម៌ ដែលជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រឈម

មានឧបសគ្គជាច្រើនដែលរារាំងការទទួលបានការជំនុំជម្រះយុត្តិធម៌នៅកម្ពុជា។ បទដ្ឋានសង្គម និងវប្បធម៌ដែលចាក់ឫសគល់ និងផ្នត់គំនិតយេនឌ័របែបអវិជ្ជមានអាចជាឧបសគ្គសម្រាប់ស្ត្រីក្នុងការដាក់ពាក្យបណ្តឹងទាក់ទងនឹងអំពើហិង្សទាក់ទងនឹងយេនឌ័រ។ នេះរាប់បញ្ចូលទាំងការស្តីបន្ទោសបង្អាប់ដល់ស្ត្រីពីអំពើទាំងនោះ ឧទាហរណ៍ ដែលថាពួកគេមិនបរិសុទ្ធ។ ទស្សនៈដែលយល់ថាទម្រង់នៃអំពើហិង្សាក្នុងគ្រួសារមួយចំនួនអាចទទួលយកបាននៅក្នុងផ្ទះ ឬដែរថាអំពើហិង្សាក្នុងគ្រួសារជាបញ្ហាក្នុងគ្រួសារដែលត្រូវទុកជាការសម្ងាត់។ ជាលទ្ធផលជនរងគ្រោះជាច្រើនមិនដែលរាយការណ៍ពីអំពើហិង្សានេះ។ បទដ្ឋានទាំងនេះក៏មាននៅក្នុងប្រព័ន្ធយុត្តិធម៌ផងដែរ។ នគរបាល ចៅក្រម ព្រះរាជអាជ្ញា ជួនកាលមានអាកប្បកិរិយារើសអើងចំពោះស្ត្រីបណ្តាលឱ្យមានការស្តីបន្ទោស ឬទំនាក់ទងដែលមិនសមរម្យដូចជាសួរជនរងគ្រោះថាហេតុអ្វីបានជាពួកគេមិនរាយការណ៍ពីការរំលោភបំពានពីដំបូង ឬ ក៏សួរពួកគេនូវសំណួរមិនសមរម្យដដែលៗ ឬក៏ការផ្តល់ប្រឹក្សាមិនសមរម្យ។ តំណាងរបស់ស្ត្រីក្នុងប្រព័ន្ធយុត្តិធម៌គ្រប់ផ្នែកនៅមានចំនួនតិចតួចខ្លាំង។




**នៅខែកុម្ភៈ ឆ្នាំ២០២០ មានចៅក្រមជាស្ត្រីចំនួន ១៥% ព្រះរាជអាជ្ញាជាស្ត្រីចំនួន ១៤% និង មេធាវីជាស្ត្រីចំនួន ២២%។**

ប្រភព៖ អគ្គលេខាធិការរដ្ឋសភាជាតិ «បញ្ហាប្រឈមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ៖ របកគំហើញសំខាន់នៃការវិភាគស្ថិតិយេនឌ័រ» (ឆ្នាំ២០២០)

# ជនជាប់ចោទជាស្ត្រី និង សិទ្ធិជំនុំជម្រះដោយយុត្តិធម៌

មិនមែនត្រឹមតែស្ត្រីប្រឈមនឹងការទទួលបានយុត្តិធម៌ចំពោះការប្រព្រឹត្តិបទល្មើសប្រឆាំងពួកគេទេ ជនជាប់ចោទជាស្ត្រីក៏ទទួលបានការគោរពសិទ្ធិជំនុំជម្រះដោយយុត្តិធម៌នេះតិចតួចផងដែរ។ ចន្លោះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ និងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ ម.ស.ម.ក បានសង្កេតសវនាការចំនួន១៥៦សំណុំរឿងនៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ មានជនជាប់ចោទ ១៩៣នាក់ ក្នុងនោះជនជាប់ចោទ ១៨នាក់ជាស្ត្រី។ ជនជាប់ចោទជាស្ត្រីមាន ១៧សំណុំរឿង។

- **ការសន្មតជាមុនថាគ្មានទោស**

  ក្នុងចំណោមជនជាប់ចោទជាស្ត្រីចំនួន១៨នាក់ ជនជាប់ចោទជាស្ត្រី ១១នាក់ (៦១.១%) បានបង្ហាញខ្លួនក្នុងសវនាការក្នុងសម្លៀកបំពាក់អ្នកទោសផ្ទុយនឹងការសន្មតជាមុនថាគ្មានទោស។( *មិនពាក់ព័ន្ធ–ជនជាប់ចោទអវត្តមាន )

- **សិទ្ធិមានមេធាវ**

  ជនជាប់ចោទជាស្ត្រីចំនួន ៤នាក់(២២.២%) ក្នុងចំណោម ១៨នាក់ មិនមានមេធាវីតំណាងដែលផ្ទុយទៅនឹងសិទ្ធិមានមេធាវី។

## តើជនជាប់ចោទបង្ហាញមុខចំពោះតុលាការក្នុងឯកសណ្ឋានអ្នកទោសដែរឬទេ?




## តើជនជាប់ចោទមានមេធាវីតំណាងដែរឬទេ?




## អនុសាសន៍ដល់រដ្ឋាភិបាលកម្ពុជា និងក្រសួងយុត្តិធម៌

១. ចាត់វិធានការផ្នែកច្បាប់និងជាក់ស្តែងប្រកបដោយប្រសិទ្ធភាពដើម្បីធានាឱ្យមានអ្នកតំណាងសម្រាប់ស្ត្រីនៅគ្រប់ផ្នែកនៃប្រព័ន្ធយុត្តិធម៌។

២. ធានាថាសេចក្តីព្រាងគោលនយោបាយជំនួយផ្នែកច្បាប់ដែលក្រសួងយុត្តិធម៌កំពុងតាក់តែង ត្រូវបញ្ចូលលទ្ធភាពទទួលបានយុត្តិធម៌ស្មើគ្នាប្រកបដោយប្រសិទ្ធភាព និងសិទ្ធិមានមេធាវីសម្រាប់ស្ត្រី។

៣. អនុវត្តតាមការប្រតិបត្តិល្អបំផុតនៅអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា(អ.វ.ត.ក)ចំពោះកិច្ចការពារសាក្សី និងជនរងគ្រោះ។

៤. អនុម័តច្បាប់ការពារសិទ្ធិនៃជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុងបរិបទនៃដំណើរការនីតិវិធីច្បាប់ដោយផ្តោតលើការគោរពឯកជនភាពទាំងការគាំទ្រផ្នែកច្បាប់និងផ្លូវចិត្ត។ ឧទាហរណ៍ដូចជា៖

ក.ការបង្កើតគោលការណ៍ណែនាំរបស់តុលាការដែលចង្អុលបង្ហាញពីការសាកសួរទាំងឡាយណា ដែលអាចត្រូវបានអនុញ្ញាតដល់ជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីបញ្ចៀសការសួរសំណួរមិនសមរម្យណាមួយ។

ខ.អនុញ្ញាតឱ្យមានអ្នកតំណាង និងអ្នកគាំទ្រជនរងគ្រោះនៅពេលពួកគាត់ត្រូវចូលរួមធ្វើជាសាក្សី។

គ.តម្រូវឱ្យតុលាការចាត់វិធានការការពារសិទ្ធិរបស់ជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ អំឡុងពេលផ្តល់ភស្តុតាង រួមមានការបង្កើតប្រព័ន្ធអនុញ្ញាតឱ្យជនរងគ្រោះផ្តល់ភស្តុតាងតាមវីដេអូ។

៥. ផ្តល់ការបណ្តុះបណ្តាលពាក់ព័ន្ធនឹងរំញោចយេនឌ័រ និងការកសាងសមត្ថភាពដល់មន្ត្រីយុត្តិធម៌ និងអ្នកអនុវត្តច្បាប់។

ប្រភព: ម.ស.ម.ក «ការសង្កេតការណ៍សវនាការសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌»
HTTP://TMP.SITHI.ORG/


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org



BY NC SA


ខែធ្នូ ឆ្នាំ២០២០